ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ក្រុមប្រតិកម្មព័ត៌មាន គ.ជ.ប
លេខ ០០៣ គ.ជ.ប

ថ្ងៃចន្ទ ១៤កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២

# សេចក្តីថ្លែងការណ៍
## គ.ជ.ប នឹងចាត់វិធានការតាមច្បាប់ ចំពោះការចោទប្រកាន់ទាំងឡាយណាដែលផ្ទុយពីការពិត

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ បានប្រព្រឹត្តទៅដោយរលូនដូចការគ្រោងទុក និងមានការទទួលស្គាល់ ទទួលយកលទ្ធផលពីគ្រប់ភាគី ព្រមទាំងមានការវាយតម្លៃខ្ពស់ពីអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិថាការបោះឆ្នោតកាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ កន្លងទៅនេះ បានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ក្នុងបរិយាកាសស្ងប់ស្ងាត់ សន្តិសុខ របៀបរៀបរយ គ្មានអំពើហិង្សា និងគ្មានការគំរាមកំហែង ហើយប្រជាពលរដ្ឋខ្មែរជាង ៨០% បានទៅបោះឆ្នោតសម្តែងឆន្ទៈរបស់ខ្លួនគួរឱ្យកត់សម្គាល់។

ជាគោលការណ៍ច្បាប់ស្តីពីការបោះឆ្នោត គ.ជ.ប បើកសិទ្ធិឱ្យគណបក្សនយោបាយ ប្តឹងជុំវិញភាពមិនប្រក្រតីណាមួយដែលខ្លួនបានសង្កេតឃើញនៅគ្រប់ដំណាក់កាលបោះឆ្នោត ពិសេសនៅថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត។ ក្នុងន័យនេះ គ.ជ.ប មានយន្តការដាក់ ទទួល និងដោះស្រាយបណ្តឹងតាមឋានានុក្រមពីថ្នាក់ឃុំ សង្កាត់ ថ្នាក់រាជធានី ខេត្ត និងថ្នាក់ គ.ជ.ប ជាពិសេសការប្តឹង ឬការដោះស្រាយពាក្យបណ្តឹងក្នុងដំណាក់កាលនៃការឃោសនាបោះឆ្នោត ដំណាក់កាលមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងដំណាក់កាលបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៅឃុំ សង្កាត់ ដូចមានចែងក្នុងច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ជាធរមាន ហើយគួរចៀសវាងថ្លែងជាការប្រមាថ បរិហារកេរ្តិ៍ជាសាធារណៈ និងញុះញង់ ដែលអាចនាំឱ្យមានការចោទប្រកាន់ដូចមានចែងក្នុងក្រមព្រហ្មទណ្ឌត្រង់មាត្រា៣០៥ និង ៣០៦ ពាក់ព័ន្ធនឹងបទបរិហារកេរ្តិ៍ជាសាធារណៈ ដូចជាតាមសម្តី ទោះជាប្រភេទណាក៏ដោយ ដែលបញ្ចេញនៅទីសាធារណៈ ឬនៅក្នុងសាលប្រជុំ... និងការបរិហារកេរ្តិ៍ដែលប្រព្រឹត្តតាមសារព័ត៌មាន និងដែលត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសារព័ត៌មាន។

បច្ចុប្បន្ននេះ គ្រប់យន្តការនៃ គ.ជ.ប បានទទួលពាក្យបណ្តឹង និងកំពុងដោះស្រាយបណ្តឹងរហូតដល់ចប់ មុននឹងប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥។ /ច



វិថីរាជសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
St., Ratsaphea Tonle Basac, Khan Chamkar Mon, Phnom Penh, Cambodia
ទូរស័ព្ទ : 023 235 271
អ៊ីម៉ែល : info@nec.gov.kh

ទន្ទឹមនឹងនេះ នៅមានបុគ្គល ឬគណបក្សនយោបាយមួយចំនួនតូចនៅបន្តចោទប្រកាន់ និងរិះគន់ គ.ជ.ប ដោយគ្មានមូលដ្ឋាន។ ជាក់ស្តែង លោក **សុន ឆ័យ** បាននិយាយដដែលជាដដែល ដូចក្នុងកម្មវិធីនៃកិច្ចសម្ភាសន៍ជាមួយសារព័ត៌មានអនឡាញ Cambodia Daily កាលពីថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២ ដោយដៃទទួលយកអាសនៈវិញមាត់ចោទថាការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នេះ មិនត្រឹមត្រូវ និងមិនយុត្តិធម៌ ហើយលោកអះអាងទៀតថា ការដែលគណបក្សភ្លើងទៀន ទទួលយកអាសនៈ គឺជាការគោរពឆន្ទៈអ្នកបោះឆ្នោត។ បើដូចនេះមែន លោក **សុន ឆ័យ** ក៏ត្រូវតែគោរពឆន្ទៈរបស់ប្រជាពលរដ្ឋជាច្រើនទៀតដែរ ដែលមិនបានបោះឆ្នោតឱ្យគណបក្សភ្លើងទៀន ហើយលោក **សុន ឆ័យ** ប្រាកដជាដឹងថានេះជាគោលការណ៍គ្រឹះនៃលទ្ធិប្រជាធិបតេយ្យ ព្រមជាមួយគ្នានេះដែរ ការបោះឆ្នោតគឺជាស្នូលនៃលទ្ធិប្រជាធិបតេយ្យ។ លោក **សុន ឆ័យ** និយាយទៀតថា *"លទ្ធផលនេះមិនឆ្លុះបញ្ចាំងអំពីឆន្ទៈប្រជាពលរដ្ឋទេ វាមានការបំភ័យ វាមានការទិញ វាមានការលួច បាននៅសល់ប៉ុណ្ណឹង"*។

ការថ្លែងបែបនេះ គ.ជ.ប មិនអាចទទួលយកបានទេ ហើយជាការមាក់ងាយ និងប៉ះពាល់ដល់តម្លៃរបស់ម្ចាស់ឆ្នោតដែលបានអញ្ជើញទៅបោះឆ្នោតយ៉ាងច្រើនកុះករ និងធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ គ.ជ.ប ដែលជាស្ថាប័នចែងក្នុងរដ្ឋធម្មនុញ្ញ ព្រមទាំងធ្វើឱ្យមានការភាន់ច្រឡំ និងបាត់ទំនុកចិត្តលើការបោះឆ្នោត ដែលបានចែងក្នុងមាត្រា ១៧១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលនឹងត្រូវផាកពិន័យជាប្រាក់ពី ១០លានរៀល ដល់ ២០លានរៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

ដើម្បីភាពស្អាតស្អំ ការរក្សាកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ស្ថាប័ន គ.ជ.ប នឹងចាត់វិធានការតាមច្បាប់ ចំពោះការចោទប្រកាន់ទាំងឡាយណាដែលផ្ទុយពីការពិត។

ចំពោះព័ត៌មានពិស្តារ សូមទាក់ទង៖


| | |
|---|---|
| ឯកឧត្តម **ឌឹម សុវណ្ណារ៉ុមុ**<br>សមាជិក គ.ជ.ប និងជាប្រធានក្រុមប្រតិកម្មព័ត៌មាន គ.ជ.ប | លេខទូរស័ព្ទ៖ (855) 012 518 485<br>អ៊ីម៉ែល៖ sovanaromhy@yahoo.fr |